*សំឡេងរបស់អ្នក, អំណាចរបស់អ្នក*

គណៈកម្មការបែងចែកក្រុមប្រឹក្សាក្រុងឡើងវិញ ក្រុងឡូសអានចែលឡេស (LACCRC)

# អ្វីដែលអ្នកត្រូវដឹងអំពី ការរៀបចំសង្កាត់ឡើងវិញ

នៅក្នុងលិទ្ធិប្រជាធិបតេយ្យ, សំឡេងរបស់យើង គឺជាអំណាចរបស់យើង។ ក្នុងនាមជាប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងឡូសអានចែលឡេស, យើងប្រើសំលេងនោះតាមរបៀបជាច្រើន - ធ្វើការបោះឆ្នោតអោយសមាជិកក្រុមប្រឹក្សា ដើម្បីតំណាងអោយយើង; ដើម្បីស្វែងរកជំនួយពីមន្ត្រីដែលយើងបានជ្រើសរើស នៅពេលដែលយើងត្រូវការ; ដើម្បីឱ្យអ្នកធ្វើសេចក្ដីសម្រេចចិត្ត ដឹងថាតើយើងគាំទ្រ ឬប្រឆាំងនឹងច្បាប់ថ្មី ឬគោលនយោបាយ ដែលជះឥទ្ធិពលលើជីវិតរបស់ពួកយើង។ **ដំណើរការរៀបចំសង្កាត់ឡើងវិញ គឺជាវិធីមួយផ្សេងទៀត ដែលយើងត្រូវប្រើសំឡេងដើម្បីអនុវត្តនូវអំណាចរបស់យើង។** ការបែងចែកសង្កាត់ឡើងវិញ គឺមានសារៈសំខាន់ចំពោះលទ្ធិប្រជាធិបតេយ្យ ដូចជាការបោះឆ្នោតដែរ។ ប៉ុន្តែមានមនុស្សជាច្រើនអ្នកណាស់ ដែលមិនបានដឹងច្រើន អំពីការបែងចែកសង្កាត់ឡើងវិញនេះឡើយ។ លាកប័ត្រព័ត៌មាននេះ មានគោលបំណងផ្ដល់ជូនអ្នក នូវព័ត៌មានសំខាន់ៗអំពីការបែងចែកសង្កាត់ឡើងវិញ, ហើយថាតើ ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះអ្នក។

## តើការបែងចែកសង្កាត់ឡើងវិញគឺជាអ្វី?




មនុស្សគ្រប់រូបនៅក្នុងទីក្រុងឡូសអានចែលឡេស រស់នៅក្នុងសង្កាត់ក្រុមប្រឹក្សាក្រុង។ យើងមានឱកាសជ្រើសរើសសមាជិកក្រុមប្រឹក្សាក្រុង ដោយផ្អែកលើសង្កាត់ណា ដែលយើងរស់នៅ។ ឧទាហរណ៍ - Boyle Heights, Pacoima, Venice, and South LA គឺស្ថិតនៅក្នុងសង្កាត់ក្រុមប្រឹក្សាផ្សេងៗគ្នា, ហើយអ្នករស់នៅក្នុងសហគមន៍ទាំងនោះ បោះឆ្នោតឱ្យមនុស្សផ្សេងគ្នា ធ្វើជាតំណាងពួកគេ។

រៀងរាល់ ១០ ឆ្នាំម្ដង, ប្រទេសទាំងមូលឆ្លងកាត់ដំណើរការមួយ ដែលហៅថាការគូសបែងចែកសង្កាត់ឡើងវិញ ដែលកំណត់នូវសង្កាត់នីមួយៗ។ នៅពេលដែលសហគមន៍មានទំហំតូច ឬធំជាងមុន ហើយប្រជាជនរើចូល និងរើចេញ, វាជាការសំខាន់ដែលត្រូវកំណត់នូវសង្កាត់ដោយយុត្តិធម៌ និងស្មើ គ្នា។ យោងតាមរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក, រាល់មណ្ឌលបោះឆ្នោតដែលមាននៅក្នុងផែនទីបែងចែកសង្កាត់ឡើងវិញ ត្រូវតែមានចំនួនប្រជាជនប្រហាក់ប្រហែលគ្នា។ ផែនទីដែលបានគូស នឹងកំណតនូវការបែងចែកអំណាចនយោបាយ និងតំណាងនៅគ្រប់កម្រិតនៃរដ្ឋាភិបាល ( ទីក្រុង, ស្រុក, រដ្ឋ, និងសហព័ន្ធ )។

## ហេតុអ្វីបានជាការបែងចែកសង្កាត់ឡើងវិញ មានសារៈសំខាន់?

ខ្សែបន្ទាត់សង្កាត់ដែលបានគូសនោះ អាចកំណត់ថាតើអ្នកណាដែលប្រជាពលរដ្ឋអាចបោះឆ្នោតអោយ ហើយថាមន្ត្រីជាប់ឆ្នោតឆ្លើយតបនឹងសំណើរបស់អ្នក ដោយរបៀបណា។ ការតំណាង គឺជាអំណាច។ ជនដែលតំណាងឱ្យអ្នក នៅក្នុងសាលាក្រុង អាចមានន័យថា ធ្វើអោយមានច្រើន ឬតិច នូវលំនៅដ្ឋានដែលមានតំលៃសមរម្យ, ដងផ្លូវស្អាត, និងមានសួនឧទ្យានល្អៗ។ ហើយត្រូវធ្វើអោយច្បាស់ថា ការគូសនូវសង្កាត់របស់អ្នក ក្នុងន័យដែលផ្ដល់ឱ្យអ្នក នូវការតំណាងត្រឹមត្រូវ ដែលអាចធ្វើឱ្យមានភាពខុសគ្នាយ៉ាងខ្លាំង សម្រាប់អ្នក និងគ្រួសាររបស់អ្នក។ គ្មានការបដិសេធនូវសំលេងរបស់អ្នក ក្នុងការបែងចែកសង្កាត់នៅក្នុងរដ្ឋាភិបាលទីក្រុងនោះឡើយ។ ត្រូវគូសផែនទី ក្នុងន័យដែលអនុញ្ញាតឱ្យសង្កាត់របស់អ្នក ទទួលបាននូវការប្រព្រឹត្តលើអោយបានស្មើៗគ្នា។







**តើការបែងចែកសង្កាត់ឡើងវិញ ដំណើរការដោយរបៀបណា?**
អភិបាលក្រុង និងក្រុមប្រឹក្សាក្រុងបានតែងតាំងគណៈកម្មការរបស់ប្រជាពលរដ្ឋដែលមានឯករាជ្យ ដើម្បីណែនាំពួកគេពីរបៀបគូរសង្កាត់ថ្មី ដែលឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍របស់សហគមន៍រាប់រយនាក់ នៅទីក្រុងឡូសអានចែលឡេស ដែលធ្វើឱ្យវាមានភាពជាក់លាក់ប្លែកពីគេ។ មានការបង្កើតឡើងដោយប្រជាពលរដ្ឋចម្រុះ មកពីគ្រប់តំបន់នៃទីក្រុង នូវគណៈកម្មការដែលមានសមាជិក ២១ នាក់។ គណៈកម្មការមានការប្តេជ្ញាចិត្ត ក្នុងការធ្វើឱ្យប្រាកដ ថាមនុស្សគ្រប់រូបមានតំណាងស្មើគ្នា និងមានភាពយុត្តិធម៌នៅក្នុងសាលាក្រុង។

មុនការគូសបន្ទាត់ឡើងវិញ, គណៈកម្មការនឹងធ្វើការប្រជុំបន្តបន្ទាប់គ្នាជាសាធារណៈ និងការប្រជុំសហគមន៍ចំនួន ១៩ លើក។ ក្នុងនោះ នឹងមានការប្រជុំម្តង សម្រាប់ក្រុមប្រឹក្សាក្រុងនីមួយៗ និងកិច្ចប្រជុំថ្នាក់តំបន់ ចំនួនបួន។

នៅពេលដែលគណៈកម្មការបានបញ្ចប់សវនាការសាធារណៈ ពួកគេនឹងទទួលយកព័ត៌មានដែលអ្នកបានផ្តល់ អមជាមួយនឹងទិន្នន័យដែលបានផ្តល់អោយដោយរដ្ឋាភិបាលសហព័ន្ធ ហើយធ្វើការគូសនូវផែនទីថ្មី។

និងធ្វើបទបង្ហាញនូវសំណុំផែនទីពង្រៀង ដល់សហគមន៍តាមអ៊ិនធឺរណិត និងតាមរយៈសវនាការសាធារណៈ ដើម្បីធានាថាគណៈកម្មការទទួលបាននូវយោបល់នានា។ បន្ទាប់មក យើងនឹងពិនិត្យផែនទីឡើងវិញ ហើយបញ្ជូនទៅអោយក្រុមប្រឹក្សាក្រុង ដើម្បីធ្វើការអនុម័ត។

**តើខ្ញុំអាចចូលរួមដោយរបៀបណា ដើម្បីប្រាកដថា គេបានឮសំលេងរបស់ខ្ញុំ?**
មានមធ្យោបាយជាច្រើនសម្រាប់អ្នក ក្នុងការចូលរួមក្នុងដំណើរការបែងចែកសង្កាត់ឡើងវិញ។

> ចូលរួមក្នុងសវនាការមួយ ក្នុងចំនោមសវនាការចំនួន ១៩, ដែលនឹងត្រូវធ្វើឡើងតាមអ៊ីនធឺរណិត នៅស្ទើរតែគ្រប់សហគមន៍ទាំងអស់ នៅទូទាំងទីក្រុងឡូសអានចែលឡេស ដែលធ្វើឡើងចន្លោះពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០២១, និងថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០២១ ។
>
> អ្នកអាចកក់ទុកជាមុន តាមគេហទំព័រ bit.ly/LACCRCMeetings ឬទូរស័ព្ទទៅកាន់ **(213) 263-5765.**
>
> នៅពេលដែលអ្នកចុះឈ្មោះ អ្នកនឹងទទួលតំណរភ្ជាប់ Zoom ដែលនឹងអនុញ្ញាតឱ្យអ្នកចូលរួមសវនាការជាសាធារណៈតាមអ៊ិនធឺរណិត, ពីទូរស័ព្ទ, កុំព្យូទ័រ, ឬឧបករណ៍ផ្សេងៗទៀតរបស់អ្នក។
>
> ផងដែរ អ្នកក៏អាចដាក់សក្ខីកម្មរបស់អ្នក ជាលាយលក្ខណ៍អក្សរទៅកាន់: redistricting.lacity@lacity.org.

ការងាររបស់គណៈកម្មការ គឺត្រូវយកយោបល់របស់អ្នកទៅពិចារណា នៅពេលបង្កើតអនុសាសន៍ស្តីពីរបៀបនៃការគូសផែនទីសង្កាត់។

យើងត្រូវដឹងអំពីអ្វីដែលអ្នកជឿថា បង្កើតបានជាសហគមន៍របស់អ្នក។ ប្រាប់យើងអំពីសាលារៀន, ព្រះវិហារ, សួនឧទ្យាន, និងតំបន់ហាងទំនិញ។ ប្រាប់យើងអំពីប្រជាជន។ ប្រាប់យើងអំពីអ្វីដែលត្រូវដាក់បញ្ចូលនៅក្នុងសង្កាត់, ហើយអ្វីដែលធ្វើឱ្យសហគមន៍របស់អ្នកជាក់លាក់ប្លែកពីគេ។

**តើមានច្បាប់ និងលក្ខណៈវិនិច្ឆ័យអ្វីខ្លះ?**
មានការប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យមួយចំនួន ដើម្បីសម្រេចចិត្តលើផែនទី រួមមាន:

1. សង្កាត់ក្រុមប្រឹក្សា ត្រូវមានទំហំប្រជាជនស្មើៗគ្នា។
2. ផ្នែកផ្សេងគ្នានៃសង្កាត់ ត្រូវមានលទ្ធភាពភ្ជាប់គ្នាទៅវិញទៅមក តាមលក្ខណៈភូមិសាស្ត្រ។
3. ត្រូវបង្រួមអោយនៅតិចជាអប្បបរមា នូវការបំបែកសង្កាត់/អ្នកជិតខាង ទៅជាសង្កាត់ដ៏ច្រើន អោយខានតែបាន។
4. អនុលោមតាមច្បាប់សិទ្ធិបោះឆ្នោត, ដែលជាច្បាប់ ដែលមានគោលបំណងក្នុងការការពារជាតិដើម ដូចជាឡាទីន, ជនជាតិអាមេរិកាំងអាស៊ី និងអាមេរិកាំងអាហ្វ្រិក ឱ្យមានឱកាសស្មើភាពគ្នា ក្នុងការជ្រើសរើសតំណាង ដោយជម្រើសរបស់ពួកគេផ្ទាល់។